**LONG BEACH UNIFIED SCHOOL DISTRICT**

**ក្រសួងអប់រំតំបន់ឡុងប៊ិច**

ផ្តល់សេវាកម្មអប់រំនៅ LONG BEACH, LAKEWOOD, SIGNAL HILL AND AVALON

ការិយាល័យអគ្គនាយកសាលា

1515 HUGHES WAY
LONG BEACH, CALIFORNIA 90810-1839
(562) 997-8242 • FAX (562) 997-8280

ថ្ងៃទី២៧ ខែមេសា ឆ្នាំ២០០៩

សូមជំរាបមកដល់មាតាបិតាឬអ្នកអាណាព្យាបាលសិស្ស:

សំបុត្រនេះផ្តល់នូវព័ត៌មានជាគោលៗអំពីគ្រុនផ្តាសាយ“ស្វាញ” (swine flu) ។ ព័ត៌មាននេះគឺជាវិធានការណ៍បង្ការការពារមួយដែលក្រសួងអប់រំយើងកំពុងប្រតិបត្តិដើម្បីធ្វើយ៉ាងណាឲ្យសិស្សានុសិស្សនិងបុគ្គលិកសាលាមានសុខភាពនិងសុវត្ថិភាពល្អ។

នៅបច្ចុប្បន្ននេះ យើងពុំឃើញមាននរណាកើតរោគផ្តាសាយ“ស្វាញ”នៅតាមសាលារៀនយើងនៅឡើយទេ។ ក៏ប៉ុន្តែយោងទៅតាមអនុសាសន៏ពីក្រសួងសុខាភិបាលក្រុងឡុងប៊ិច យើងសូមរំលឹកលោកអ្នកអំពីវិធីបង្ការការពារខាងក្រោមនេះដើម្បីការពារគ្រួសារលោកអ្នកពីរោគនេះ:

- រំលឹកឲ្យកូនលាងដៃជាញឹកញាប់ ហើយឲ្យគ្របមាត់និងច្រមុះឲ្យជិតនៅពេលក្អកនិងពេលកណ្តាស់។
- ទុកកូនឲ្យនៅផ្ទះបើកូនឈឺ ឬមានរោគសញ្ញាដូចគ្រុនផ្តាសាយ(រួមទាំងក្តៅខ្លួន ឈឺខ្លួនប្រាណ ក្អកនិងហៀរសំបោរ។
- ផ្តាំកូនកុំឲ្យនៅជិតមនុស្សឈឺ គឺឲ្យនៅយ៉ាងតិចចំងាយពាហ្វីទពីមនុស្សឈឺ។
- កុំផ្អើលឆោឡោរហើយអប់រំណែនាំកូនកុំឲ្យមានការភិតភ័យ។

អភិបាលនិងពេទ្យប្រចាំសាលានៅគ្រប់សាលារៀនត្រូវបានប្រាប់ឲ្យប្រុងសង្កេតមើលក្រែងលោមានសិស្សឬបុគ្គលិកណាដែលមានរោគសញ្ញាគ្រុនផ្តាសាយ ហើយឲ្យតាមដានស៊ើបសួរអ្នកណាដែលឈប់ពុំបានមករៀនផងដែរ។ សាលារៀននឹងផ្ញើព័ត៌មានថែមទៀតអំពីរឿងនេះតាមកូនលោកអ្នកពេលចេញទៅផ្ទះ។

ដើម្បីព័ត៌មានក្បោះក្បាយថែមទៀត សូមឡើងទៅគេហទំព័រនៃអង្គការត្រួតត្រារោគជំងឺនៅ www.cdc.gov/swineflu. ថែមពីនោះទៀត លោកអ្នកក៏អាចរកមើលព័ត៌មានថ្មីៗនៅគេហទំព័រក្រសួងអប់រំនៅ www.lbschools.net ។

សូមអរគុណដល់ការគាំទ្រជាបន្តរបស់លោកអ្នកមកដល់សិស្សានុសិស្សនិងបុគ្គលិកសាលាយើង។ សុខភាពហើយនិងសុវត្ថិភាពរបស់ពួកគេគឺជាអាទិភាពខ្ពស់ជាងគេបង្អស់របស់យើង។

ដោយសេចក្តីស្មោះចំពោះ,



Christopher J. Steinhauser
អគ្គនាយកសាលា